**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

# សេចក្តីប្រកាសព័ត៌មាន

នៅព្រឹកថ្ងៃព្រហស្បតិ៍ ១៥កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ **ឯកឧត្តម ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់នៅក្នុងពិធីបើកសិក្ខាសាលាផ្សព្វផ្សាយស្តីពីការចាប់ផ្តើមអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី៣ (LASED III) តាមប្រព័ន្ធអនឡាញ ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំនិងក្រុមការងារក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារពិភពលោក តំណាងក្រសួង ស្ថាប័នចំណុះគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អភិបាលនៃគណៈអភិបាលខេត្ត ព្រមទាំងតំណាងមន្ទីរ អង្គភាពពាក់ព័ន្ធចំណុះរដ្ឋបាលខេត្ត រដ្ឋបាលស្រុក និងឃុំពាក់ព័ន្ធ សហគមន៍ជនជាតិដើមភាគតិច ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអង្គការអន្តរជាតិមួយចំនួនទៀត។

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី៣ ជាគម្រោងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានថវិកាសរុប ១០៧ លានដុល្លារអាមេរិក ក្នុងនោះឥណទានធនាគារពិភពលោកចំនួន ៩៣លានដុល្លារ និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជាចំនួន ១៤លានដុល្លារ សហការអនុវត្តដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់រយៈពេល ៦ឆ្នាំ ពីខែតុលា ឆ្នាំ២០២០ ដល់ខែធ្នូ ឆ្នាំ២០២៦ ក្នុងភូមិសាស្ត្រខេត្តគោលដៅដែលមានដីសមស្រប និងនៅទីតាំងចំនួន ៧១ ក្នុងនោះ ២៦ទីតាំង សម្រាប់ការងារសម្បទានដីសង្គមកិច្ច និង ៤៥ទីតាំង សម្រាប់សហគមន៍ជនជាតិដើមភាគតិច មានផ្ទៃដីសរុប ៣០ ០០០ហិកតា ក្នុងនោះផ្ទៃដីសហគមន៍ជនជាតិដើមភាគតិច១០ ០០០ហិកតា និងមានអ្នកទទួលផលសរុប ៦ ៥០០គ្រួសារ ក្នុងនោះសហគមន៍ជនជាតិដើមភាគតិច ១ ៥០០គ្រួសារ។ សកម្មភាពរបស់គម្រោងផ្តោតលើការងារសំខាន់ចំនួន ៥ គឺការងារសម្បទានដីសង្គមកិច្ច, ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច, ការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ, ការអភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការគាំទ្រដល់ការអភិវឌ្ឍជីវភាពរស់នៅរបស់អ្នកទទួលផល។


អាសយដ្ឋាន : ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

តាមរយៈការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចប្រកបដោយតម្លាភាព និងអភិបាលកិច្ចល្អ គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី៣ នឹងផ្តល់ដីសម្រាប់លំនៅឋាននិងដីសម្រាប់កសិកម្មដល់ប្រជាជនក្រីក្រ សម្រាប់ជាទុនក្នុងការចាប់ផ្តើមកសាងជីវភាពរស់នៅនិងបង្កបង្កើនផល។ ជាមួយនេះ គម្រោងនឹងរួមចំណែកសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាមូលដ្ឋាន បណ្តុះបណ្តាលលើការងារកសិកម្មនិងធ្វើការផ្សារភ្ជាប់ជាមួយទីផ្សារ ដើម្បីបង្កើនប្រាក់ចំណូល លើកកម្ពស់កម្រិតជីវភាពរស់នៅ កាត់បន្ថយចំណាកស្រុក និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ចូលរួមសម្រេចគោលបំណងនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ដែលជារបៀបវារៈសង្គមសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១

# សុន្ទរកថា

## របស់ឯកឧត្តម ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មការដឹកនាំគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី៣ ក្នុងពិធីបើកសិក្ខាសាលាផ្សព្វផ្សាយស្តីពីការចាប់ផ្តើមអនុវត្តគម្រោង LASED III

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ត្រូវនឹងថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ៨:៣០ តាមអនឡាញ

- ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- លោកស្រី **Mariam Sherman** នាយិកាធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា មីយ៉ាន់ម៉ា និងឡាវ
- លោកស្រី **Inguna Dobraja** ប្រធានគ្រប់គ្រងធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា
- ឯកឧត្តមរដ្ឋលេខាធិការ
- ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័នរាជរដ្ឋាភិបាលនៅក្នុងគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ
- ឯកឧត្តម **រ័ត្ន ហុក** អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជានាយកគម្រោង LASED III
- ឯកឧត្តម **ប៉ែន ធីរុទ្ធ** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លោកស្រី **ចំរើន មុនិតា** ប្រធានក្រុមគ្រប់គ្រងគម្រោងនៃធនាគារពិភពលោក
- ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលខេត្ត
- ឯកឧត្តម លោកជំទាវ អភិបាលរង
- លោក លោកស្រី តំណាងអង្គការដៃគូជាតិនិងអន្តរជាតិ
- លោក លោកស្រី ប្រធានមន្ទីរ អង្គភាពចំណុះរដ្ឋបាលខេត្ត
- លោក លោកស្រី តំណាងសហគមន៍និងអ្នកទទួលផល
- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញា

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយបានចូលរួមជាមួយ ឯកឧត្តម លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ក្នុងសិក្ខាសាលាផ្សព្វផ្សាយស្តីពីការចាប់ផ្តើមអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី៣ (LASED III) ដែលរៀបចំឡើងដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងធនាគារពិភពលោក តាមអនឡាញនាឱកាសនេះ។

សិក្ខាសាលារបស់យើងប្រព្រឹត្តទៅនៅពេលដែលព្រះរាជាណាចក្រកម្ពុជាកំពុងមានឯកភាពជាតិ និងទឹកដី ស្ថិតក្នុងសន្តិភាពពេញបរិបូរណ៍ មានសន្តិសុខនិងសណ្តាប់ធ្នាប់សង្គមល្អប្រសើរ ដែលជាផលនៃនយោបាយឈ្នះ ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានដឹកនាំស្តារនិងអភិវឌ្ឍប្រទេសជាតិឡើងវិញពីបាតដៃទទេ រហូតធ្វើឱ្យប្រជាជនកម្ពុជាបានរស់នៅក្នុងជីវភាពថ្លៃថ្នូរ និងប្រទេសជាតិមានការអភិវឌ្ឍលើគ្រប់វិស័យដូចពេលបច្ចុប្បន្ន។ មន្ត្រីរាជការគ្រប់ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋ ជឿជាក់ថាសន្តិភាពនិងស្ថិរភាពខាងនយោបាយ មានតម្លៃពិតប្រាកដមិនអាចកាត់ថ្លៃបាន និងជាមូលដ្ឋានគ្រឹះមិនអាចខ្វះបាន សម្រាប់កម្ពុជាធ្វើដំណើរលើមាគ៌ានៃការគោរពសិទ្ធិមនុស្ស ការពង្រឹងនីតិរដ្ឋនិងលទ្ធិប្រជាធិបតេយ្យ ការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ដើម្បីចូលរួមចំណែកថែរក្សាសន្តិភាពនិងស្ថិរភាពក្នុងតំបន់និងពិភពលោក។ ជាមួយនឹងសេចក្តីរីករាយដែលទទួលបានពីមនុញ្ញផលទាំងឡាយលើគ្រប់វិស័យដែលរាជរដ្ឋាភិបាលផ្តល់ជូន តាមរយៈការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤** ដែលជារបៀបវារៈអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជារបស់រាជរដ្ឋាភិបាល នៅក្នុងនីតិកាលទី៦នៃរដ្ឋសភា ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ បាននិងកំពុងបង្ហាញឱ្យឃើញនូវសាមគ្គីភាពរឹងមាំនិងជំនឿជឿជាក់លើការដឹកនាំរបស់រាជរដ្ឋាភិបាល ក្នុងកិច្ចការពារ ថែរក្សាសុខសន្តិភាពនិងស្ថិរភាពសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ច ជាពិសេសក្នុងដំណាក់កាលនៃការប្រយុទ្ធប្រឆាំងនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ នាពេលបច្ចុប្បន្ន។

ជាមួយនឹងកំណើនសេដ្ឋកិច្ចជាមធ្យមប្រមាណ ៧% ក្នុងមួយឆ្នាំ ក្នុងរយៈពេលជាង ២ទសវត្សរ៍កន្លងមកនេះ អត្រានៃភាពក្រីក្របានធ្លាក់ចុះជាលំដាប់ពី ៥៣% ក្នុងឆ្នាំ ២០០៤ មកត្រឹម ១៣,៥% ក្នុងឆ្នាំ ២០១៤ ហើយនាពេលថ្មីៗកន្លងទៅនេះ ត្រូវបានប៉ាន់ស្មានថាធ្លាក់ចុះមកក្នុងរង្វង់ប្រមាណ ១០% ហើយនឹងបន្តកាត់បន្ថយ ១%ក្នុងមួយឆ្នាំ។ កត្តាទាំងនេះគឺជាបច្ច័យល្អ សម្រាប់ជួយជំរុញសម្រេចមហិច្ឆតារបស់រាជរដ្ឋាភិបាល ក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅក្នុងឆ្នាំ ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅក្នុងឆ្នាំ ២០៥០។ ឈរលើមូលដ្ឋាននៃកំណើនសេដ្ឋកិច្ចដែលកាន់តែមានពិពិធកម្មច្រើន គម្លាតនៃចំណូលក្នុងចំណោមប្រជាជនស្ថិតក្នុងកម្រិតទាប តាមរយៈការបែងចែកផលនៃកំណើនសេដ្ឋកិច្ចដល់ប្រជាជនគ្រប់ស្រទាប់។ ទោះជាស្ថិតនៅក្នុង

ស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលនៅតែមានភាពធន់ខាងផ្នែកសេដ្ឋកិច្ច និងរក្សាការបើកបៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ២ដងក្នុងមួយខែ ព្រមទាំងមានលទ្ធភាពឧបត្ថម្ភសាច់ប្រាក់និងសម្ភារៈចាំបាច់នានា ដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីការរីករាលដាលនៃជំងឺកូវីដ-១៩ទៀតផង។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី!**

នៅក្នុងគោលដៅជាយុទ្ធសាស្ត្ររបស់ខ្លួន រាជរដ្ឋាភិបាលប្តេជ្ញាកាត់បន្ថយភាពក្រីក្រឱ្យស្ថិតនៅក្នុងអត្រាទាបជាង ១០% និងការពារមិនឱ្យភាពក្រីក្រវិលត្រឡប់មកវិញ ដោយផ្តោតលើការលើកកម្ពស់ការចូលរួមក្នុងយន្តការទីផ្សារ ការអនុវត្តគោលនយោបាយគាំពារសង្គម ការកាត់បន្ថយបន្ទុកជីវភាពរស់នៅ ការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព និងការកាត់បន្ថយគម្លាតសង្គម។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បាននិងកំពុងបំពេញបេសកកម្មក្នុងសមត្ថកិច្ចរបស់ខ្លួន ចូលរួមជាមួយរាជរដ្ឋាភិបាល ដើម្បីសម្រេចគោលដៅជាយុទ្ធសាស្ត្រខាងលើក្នុងវិស័យដីធ្លី រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងលំនៅឋាន ដែលជាវិស័យដ៏សំខាន់ និងជាសរសៃឈាមក្នុងការលើកកម្ពស់ភាពសុខដុមរមនានៅក្នុងសង្គម សុខុមាលភាពរបស់ប្រជាពលរដ្ឋ ជំរុញធុរកិច្ច និងទ្រទ្រង់សេដ្ឋកិច្ច និងជាវិស័យដែលបានចូលរួមចំណែកយ៉ាងធំធេងក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ ការកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈពីមួយថ្ងៃទៅមួយថ្ងៃ។

ក្នុងចំណោមការងារសំខាន់ៗស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ការងារសម្បទានដីសង្គមកិច្ចគឺជាការងារស្នូលមួយដែលរាជរដ្ឋាភិបាលតែងយកចិត្តទុកដាក់ជាប្រចាំ ដើម្បីធានាសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាប័ន្ន។ ជារួម គិតពីពេលចាប់ផ្តើមរហូតដល់ដំណាច់ខែឧសភា ឆ្នាំ២០២១ កម្មវិធីសម្បទានដីសង្គមកិច្ចគ្រប់ប្រភេទរបស់រាជរដ្ឋាភិបាល សម្រេចផ្តល់ដីសរុបទំហំ **១,៣ លាន ហិកតា** ជូនប្រជាពលរដ្ឋក្រីក្រសរុបជិត **៥០ម៉ឺនគ្រួសារ** និងសាងសង់ផ្ទះជូនប្រជាពលរដ្ឋសរុបចំនួន **៧ ៧៦៩ ខ្នង**។ សម្បទានិកចូលទៅស្នាក់នៅបានចំនួន **៦ ៣១១ ខ្នង** ស្មើនឹង **៨១,២៣%** តាមរយៈចំនួនកម្មវិធីចំនួន៤ គឺ ទី១-កម្មវិធីសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ទី២-កម្មវិធីសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រស៊ីវិលទូទៅ ទី៣-កម្មវិធីអភិវឌ្ឍតាមបណ្តោយព្រំដែន រួមមានខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តស្វាយរៀង និងខេត្តស្ទឹងត្រែង និងទី៤-គម្រោងបែងចែកដីដើម្បីសង្គមកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ច (គម្រោង LASED) ក្រោមការគាំទ្រពីធនាគារពិភពលោក។

**គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី៣** ជាគម្រោងរបស់រាជរដ្ឋាភិបាលដែលត្រូវបានរៀបចំឡើងក្នុងទស្សនាទានមិនខុសឆ្ងាយពីគម្រោង LASED ដំណាក់កាលពីរមុនឡើយ។ គម្រោងនេះ មានថវិកាសរុប ១០៧ លានដុល្លារ ក្នុងនោះឥណទានធនាគារពិភពលោកចំនួន ៩៣លានដុល្លារ និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលចំនួន ១៤លានដុល្លារ សហការអនុវត្តដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់រយៈពេល ៦ឆ្នាំ ពីខែតុលា ឆ្នាំ២០២០ ដល់ខែធ្នូ ឆ្នាំ២០២៦ នៅក្នុងភូមិសាស្ត្រខេត្តដែលមានដីសមស្រប លើកលែងតែរាជធានីភ្នំពេញ នៅ ៧១ទីតាំង ក្នុងនោះ ២៦ទីតាំង សម្រាប់ការងារសម្បទានដីសង្គមកិច្ច និង ៤៥ទីតាំង សម្រាប់សហគមន៍ជនជាតិដើមភាគតិចមានផ្ទៃដីសរុប ៣០ ០០០ហិកតា ក្នុងនោះផ្ទៃដីសហគមន៍ជនជាតិដើមភាគតិច ១០ ០០០ហិកតា និងមានអ្នកទទួលផលសរុប ៦ ៥០០គ្រួសារ ក្នុងនោះសហគមន៍ជនជាតិដើមភាគតិច ១ ៥០០គ្រួសារ ដែលផ្ដោតសំខាន់លើការងារចំនួន ៥ គឺ ការងារសម្បទានដីសង្គមកិច្ច, ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច, ការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ, ការអភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការគាំទ្រដល់ការអភិវឌ្ឍជីវភាពរស់នៅរបស់អ្នកទទួលផលពីគម្រោង។

ខ្ញុំសុំឆ្លៀតឱកាសដ៏មានតម្លៃនេះ ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកស្រី **Victoria Kwakwa** អនុប្រធានធនាគារពិភពលោក ទទួលបន្ទុកតំបន់អាស៊ីខាងកើតនិងប៉ាស៊ីហ្វិក ដែលបានព្រមទទួលយកនូវទស្សនាទានសំខាន់ៗមួយចំនួនរបស់ខ្ញុំផ្ទាល់ ក្នុងការរៀបចំគម្រោងមួយនេះឱ្យលេចជារូបរាងឡើង។

ពិនិត្យជារួម កម្មវិធីសម្បទានដីសង្គមកិច្ចតាមរយៈគម្រោង LASED បានផ្ដល់នូវ **តម្លៃបន្ថែម** ដល់ដំណើរការបែងចែកដីរដ្ឋជូនទៅប្រជាពលរដ្ឋក្រីក្រ និងធ្វើឱ្យគម្រោងនេះមានលក្ខណៈកាន់តែល្អប្រសើរ ព្រោះថា÷

- ទី១- ដំណើរការអនុវត្តគម្រោងឈរលើគោលការណ៍តម្លាភាពនិងអភិបាលកិច្ចល្អ ព្រោះគម្រោងមានច្បាប់ និងលិខិតបទដ្ឋានរបស់រាជរដ្ឋាភិបាលជាមូលដ្ឋានសម្រាប់អនុវត្ត។
- ទី២- ជាគម្រោងដែលគាំទ្រដល់គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ព្រោះជាកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយអ្វីៗត្រូវចាប់ផ្ដើមចេញពីថ្នាក់ឃុំ។ ឃុំជាអ្នកស្នើសុំទីតាំងដីសមស្រប ដើម្បីចូលក្នុងគម្រោង និងជាអ្នកជ្រើសរើសមុខសញ្ញាអ្នកទទួលផល និងសម្របសម្រួលសព្វបែបយ៉ាងជាមួយប្រជាពលរដ្ឋ។

ទី៣- ការគាំទ្រផ្នែកជំនាញកសិកម្មជាលក្ខណៈប្រព័ន្ធនៅទីតាំងអនុវត្តគម្រោង ដោយមានការបណ្តុះបណ្តាល ការផ្តល់ពូជដំណាំនិងពូជសត្វ ការតាមដាននិងសេវាថែទាំដំណាំនិងសត្វ និងមានការតភ្ជាប់មកទីផ្សារ។

ទី៤- គម្រោងផ្តល់ការគាំទ្រលើផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលជាមូលដ្ឋានចាំបាច់ក្នុងការចាប់ផ្តើមជីវភាពរស់នៅ បង្កបង្កើនផល ការធ្វើដំណើរទៅសាលារៀន ទៅមណ្ឌលសុខភាព ការដឹកកសិផលទៅកាន់ទីផ្សារ ក៏ដូចជាការទាក់ទាញភ្ញៀវទេសចរផងដែរ។

ទី៥- ការផ្តល់ជាមូលនិធិសម្រាប់ការអភិវឌ្ឍសហគមន៍ (Community Development Fund) ដែលជាដើមទុនចាំបាច់សម្រាប់ការងារកសិកម្ម និងសិប្បកម្ម។

ទី៦- ការផ្តល់កញ្ចប់ថវិកាសម្រាប់គាំទ្រលើការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ការរៀបចំដីបម្រុងសម្រាប់បង្កើតសហគមន៍ព្រៃឈើ និងការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ ដែលជាឧបករណ៍ចាំបាច់សម្រាប់ការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ និងប្រកបដោយចីរភាពនៅមូលដ្ឋាន។

ជាការកត់សម្គាល់ **គម្រោងបែងចែកដីដើម្បីសង្គមកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ច**នេះ ពិតជាបាន÷

ទី១- ចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ធ្វើឱ្យកម្រិតជីវភាពនិងគុណភាពជីវិតរបស់សម្បទានិកបានប្រសើរឡើង។

ទី២- ការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋនៅក្នុងតំបន់គោលដៅនៃគម្រោង ត្រូវបានកាត់បន្ថយគួរឱ្យកត់សម្គាល់។

ទី៣- ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ត្រូវបានពង្រីកជាលំដាប់នៅតាមជនបទប្រកបដោយគុណភាព និងធន់នឹងការប្រែប្រួលអាកាសធាតុ។

ទី៤- បរិស្ថានធម្មជាតិ ត្រូវបានការពារបានល្អប្រសើរជាងមុន តាមរយៈការរៀបចំបែងចែកដីស្របតាមគោលនយោបាយ ផែនការ និងលិខិតបទដ្ឋានរបស់រាជរដ្ឋាភិបាល ជាជាងការចូលទន្ទ្រានកាន់កាប់ដីរដ្ឋបែបអាណាធិបតេយ្យ។

ក្នុងនាមក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្ររបស់ធនាគារពិភពលោកដល់គម្រោង LASED ចាប់តាំងពីដំណាក់កាលសាកល្បងដែលបានចាប់ផ្តើមនៅឆ្នាំ ២០០៨ រហូតមកដល់ដំណាក់កាលទី៣ នេះ ដែលចាប់ផ្តើមអនុវត្តពីខែតុលាឆ្នាំ២០២០ ដល់ខែធ្នូ ឆ្នាំ២០២៦។

ខ្ញុំសូមអបអរសាទរ កោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងនិងការប្ដេជ្ញាចិត្តខ្ពស់របស់ក្រុមការងារនៃក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងក្រុមការងារធនាគារពិភពលោកក្នុងការអនុវត្តគម្រោង LASED ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព ជាពិសេសនៅដំណាក់កាលទី២កន្លងទៅ និងសុំលើកទឹកចិត្តឱ្យបន្តប្រពៃណីល្អនេះ ដើម្បីសម្រេចការអនុវត្តគម្រោងដំណាក់កាលទី៣បានកាន់តែល្អប្រសើរថែមទៀត។

ឆ្លៀតឱកាសដ៏ប្រសើរនេះ ខ្ញុំសុំផ្ដាំផ្ញើលើចំណុចមួយចំនួនដូចខាងក្រោម÷

ទី១- ស្នើឯកឧត្តម លោកជំទាវ ជាអភិបាលនៃគណៈអភិបាលខេត្តនិងជាប្រធានគណៈកម្មាធិការប្រើប្រាស់និងបែងចែកដីថ្នាក់ខេត្ត ត្រូវយកចិត្តទុកដាក់គ្រប់គ្រងការពារដីរដ្ឋដែលជាមុខសញ្ញាសម្រាប់កម្មវិធីសម្បទានសង្គមកិច្ច ដោយត្រូវបោះបង្គោល ដាក់ប៉ាណូ និងមានវិធានការចំពោះអ្នកទន្ទ្រានដីរដ្ឋខុសច្បាប់។

ទី២- អង្គភាពអនុវត្តគម្រោងគ្រប់ថ្នាក់ គ្រប់ផ្នែក ត្រូវអនុវត្តឱ្យគម្រោងឱ្យបានត្រឹមត្រូវតាមបែបបទនិងនីតិវិធីនៃកម្មវិធីសម្បទានដីសង្គមកិច្ច ដូចមានកំណត់នៅក្នុងអនុក្រឹត្យលេខ ១៩ អនុក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច ព្រមទាំងលិខិតបទដ្ឋាន និងគោលការណ៍ណែនាំពាក់ព័ន្ធជាធរមាន។

ទី៣- សុំឱ្យមន្ទីរ អង្គភាពជាសមាជិកគណៈកម្មាធិការប្រើប្រាស់និងបែងចែកដីថ្នាក់ខេត្តទាំងអស់ លើកផែនការ និងចូលរួមគាំទ្រទាំងស្មារតី និងបច្ចេកទេសដល់អង្គភាពអនុវត្តគម្រោងគ្រប់ថ្នាក់ ទៅតាមជំនាញរៀងៗខ្លួន។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជាថ្មីម្តងទៀត ចំពោះថ្នាក់ដឹកនាំនិងមន្ត្រីនៃធនាគារពិភពលោកនិងឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានចូលរួមក្នុងកម្មវិធីនាថ្ងៃនេះ។

ខ្ញុំសូមប្រសិទ្ធពរឱ្យសិក្ខាសាលាដំណើរការទៅដោយរលូន និងទទួលបានជោគជ័យល្អប្រសើរតាមការរំពឹងទុក។

ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី ទទួលបានសុខភាពល្អ និងសិរីសួស្តី ជាពិសេសចៀសផុតពីជំងឺឆ្លងកាចសាហាវទាំងពួង។

ខ្ញុំសូមប្រកាសបើកសិក្ខាសាលាផ្សព្វផ្សាយស្តីពី “**ការចាប់ផ្តើមអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី៣**” ចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**